ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សេចក្ដីប្រកាសព័ត៌មាន

យោងលិខិតលេខ ២០៥/១៨ ល.ស និងលិខិតលេខ ២០៦/១៨ ល.ស ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០១៨ របស់រដ្ឋបាលខេត្តកោះកុង សំណូមពររបស់ក្រុមប្រជាពលរដ្ឋ ៣១៦ គ្រួសារ ស្ថិតនៅស្រុកស្រែអំបិល ស្រុកបុទុមសាគរ ខេត្តកោះកុង និងសំណូមពររបស់ក្រុមប្រជាពលរដ្ឋ ១៧០ គ្រួសារ ស្ថិតនៅស្រុកស្រែអំបិល ខេត្តកោះកុង ដែលមានវិវាទដីធ្លីជាមួយក្រុមហ៊ុន Koh Kong Plantation Co.,Ltd និងក្រុមហ៊ុន Koh Kong Sugar Industry Co.,Ltd ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចាត់ក្រុមការងារចុះសហការជាមួយក្រុមការងាររបស់អាជ្ញាធរខេត្តកោះកុង ដើម្បីពិនិត្យអត្តសញ្ញាណអ្នកកាន់កាប់និងដី ពាក់ព័ន្ធនឹងករណីវិវាទខាងលើ ចាប់ពីថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០១៨ រហូតរួចរាល់ជាស្ថាពរ ឈានទៅដោះស្រាយបញ្ចប់ ។

អាស្រ័យហេតុនេះ សូមប្រជាពលរដ្ឋ ជ្រាប និងសហការជាមួយក្រុមការងារ។

ថ្ងៃសុក្រ ៤កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០១៨

អាសយដ្ឋាន : ផ្លូវលេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com